# សេចក្តីប្រកាសព័ត៌មាន (ទី២)

កាលពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៩ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានសំរាប់កម្ពុជា បានដឹកនាំគណៈប្រតិភូ ទៅចូលរួមសន្និសីទលើកទី៧ របស់អង្គការពាណិជ្ជកម្មពិភពលោក ដោយមានការចូលរួមពីបណ្តាប្រទេសអភិវឌ្ឍន៍ ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសក្រីក្រ ទាំងអស់ចំនួន ១៥៣ ប្រទេស ដែលប្រារព្ធធ្វើនៅទីក្រុង ហ្សឺណែវ ប្រទេសស្វីស ចាប់ពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៩ ។

ឆ្លៀតក្នុងឱកាសនោះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានប្រជុំពិភាក្សាការងារជាមួយបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ហើយបានស្នើឱ្យបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចំរើនខ្ពស់ និងអង្គការផ្តល់ជំនួយធំៗមួយចំនួន ដូចជាសហរដ្ឋអាមេរិក ជប៉ុន សហគមន៍អឺរ៉ុប និងរដ្ឋមន្ត្រីនៃបណ្តាប្រទេសដទៃទៀត បន្ថែមជំនួយដល់ប្រទេសក្រីក្រទាំងអស់ពី លើទឹកប្រាក់ដែលខ្លួនបានសន្យាកន្លងមក ព្រមទាំងធ្វើការកែទំរង់ក្រុមប្រឹក្សាលេខាធិការដ្ឋាន ផ្តល់ជំនួយបច្ចេកទេស សម្រាប់ពង្រឹងការធ្វើសមាហរណកម្ម ដោយត្រូវបញ្ចូលសមាជិកមកពីតំណាងប្រទេសអភិវឌ្ឍន៍តិចតួច នៅអាស៊ីមួយសមាជិក ពីតំណាងប្រទេសអាហ្វ្រិកមួយសមាជិក ពីតំណាងប្រទេសកូនកោះមួយសមាជិក និងពីតំណាងប្រទេសដែលជា អ្នកសម្របសម្រួលនៃប្រទេសក្រីក្រ ដែលបច្ចុប្បន្ន គឺប្រទេសហ្សាំប៊ៀ មួយសមាជិកផងដែរ ដើម្បីអាចឱ្យប្រទេសក្រីក្រ នៅអាស៊ីមានសំឡេងច្រើនអាចរក្សាតុល្យភាពផលប្រយោជន៍ជាមួយបណ្តាប្រទេសអាហ្វ្រិក។ ប្រទេសអភិវឌ្ឍន៍ខ្ពស់ត្រូវ បន្តផ្តល់ជំនួយដល់ប្រទេសអភិវឌ្ឍន៍តិចតួច និងប្រទេសកំពុងសុំចូលជាសមាជិកអង្គការ WTO តាមយន្តការពហុភាគី ឬ ទ្វេភាគី ដើម្បីអាចឱ្យពួកគេបានទទួលផលប្រយោជន៍ពីអង្គការនេះ។ ក្នុងនោះ ដើម្បីអាចឱ្យប្រទេសអភិវឌ្ឍន៍តិចតួច អាចមានសមត្ថភាពផលិត ផលិតផលនាំចេញទៅប្រទេសសមាជិកដទៃទៀត បានប្រទេសអភិវឌ្ឍន៍ខ្ពស់ បានសន្យាបន្តផ្តល់ជំនួយ ក្រោមក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍ពាណិជ្ជកម្ម (aid for Trade) និងជំនួយ ក្នុងក្របខ័ណ្ឌសមាហរណកម្ម (Enhance Integrated Framework) ។

**នៅក្នុងអង្គសន្និសីទ រដ្ឋមន្ត្រីទាំងអស់បានផ្តល់សារៈសំខាន់លើបញ្ហាមួយចំនួនដូចជាៈ**

- ត្រូវតែចរចាបញ្ចប់នូវរបៀបវារៈទីក្រុងដូហា ឱ្យបាននៅឆ្នាំ ២០១០ ដែលក្នុងនោះរួមមានការកាត់បន្ថយពន្ធគយលើផលិតផលកសិកម្ម និងមិនមែនកសិកម្ម ការដករបាំងលើពាណិជ្ជកម្មផ្នែកសេវាកម្ម ការផ្តល់សម្បទានដោយមិនយកពន្ធគយ និងមិនកំណត់កូតាចំពោះផលិតផលពីប្រទេសក្រីក្រ ព្រមទាំងស្នើឱ្យប្រទេសអភិវឌ្ឍន៍ខ្ពស់ធ្វើការ កាត់បន្ថយ ឬលុបបំបាត់ទាំងស្រុងនូវការឧបត្ថម្ភធនក្នុងស្រុកចំពោះកសិផល និងផលិតផលនាំចេញ។ ដែលការធ្វើបែបនេះ នឹងអាចជួយដល់ការស្តារសេដ្ឋកិច្ចប្រទេសក្រីក្រឡើងវិញពីផលប៉ះពាល់នូវវិបត្តិហិរញ្ញវត្ថុសាកលលោក។
- ការធ្វើសមាហរណកម្មក្នុងតំបន់ពិតជាបានជួយបំពេញឱ្យការធ្វើពាណិជ្ជកម្មក្នុងក្របខ័ណ្ឌពិភពលោក តែត្រូវតែធ្វើឱ្យបានស៊ីជំរៅ មានតំម្លាភាព និងជួយបំពេញគ្នាទៅវិញទៅមក ព្រមទាំងត្រូវត្រួតពិនិត្យមើលជារៀងរាល់ឆ្នាំ ។
- ស្នើឱ្យអង្គការ WTO ធ្វើការពង្រឹងសមត្ថភាពស្ថាប័ន និងប្រសិទ្ធិភាពការងារ ដោយខិតខំធ្វើការងារត្រួតពិនិត្យ និងវិភាគឱ្យបានច្រើនជាងមុន សំដៅបញ្ជៀសកុំឱ្យមានសេដ្ឋកិច្ចបែបការពារនិយមកើតឡើងក្នុងអង្គការ WTO ជាពិសេសនៅពេលប្រទេសនីមួយៗជួបនឹងវិបត្តិហិរញ្ញវត្ថុ ។
- ការផ្តល់វិភាគទានដ៏សំខាន់របស់អង្គការ WTO លើបញ្ហាបរិស្ថាន និងការប្រែប្រួលបរិយាកាស គឺអាចធ្វើឡើងតាមរយៈការលើកទឹកចិត្ត និងដកចេញនូវរបាំងទាំងឡាយ ដែលជាឧបសគ្គដល់ការធ្វើពាណិជ្ជកម្មទំនិញ និងសេវាដែលមិនប៉ះពាល់ដល់បរិស្ថាន ហើយជាមួយនោះ ត្រូវខិតខំធានាសុវត្ថិភាពស្បៀងអាហារនៅលើពិភពលោក។

លទ្ធផលសម្រេចបានខាងលើ ដោយសារកិច្ចខិតខំរបស់គណៈប្រតិភូកម្ពុជា ដែលដឹកនាំដោយឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងស្ថានតំណាងបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំនៅទីក្រុង ហ្សឺណែវ ប្រទេសស្វីស ។